# 13 សន្យាមិនពិត នៃអាហារបង្កាត់ពូជ

**នៅក្នុងជំពូកនេះ :** **ទំព័រ**


សាច់រឿង : កសិករប្រឆាំងនឹងកប្បាសបង្កាត់ពូជ........................ 238
ការបណ្តុះរុក្ខជាតិតាមបែបបុរាណ ................................ 239
តើរុក្ខជាតិបង្កាត់ពូជខុសពីការចិញ្ចឹមរុក្ខជាតិតាមបែបបុរាណយ៉ាងដូចម្តេច? .......... 240
ការចំណាយខ្ពស់លើដំណាំបង្កាត់ពូជ ................................ 240
អាហារបង្កាត់ពូជ និងសុខភាព .....................................241
សាច់រឿង : ស្រូវមាសនៅអាស៊ី ................................ 242
បញ្ហាបរិស្ថានបណ្តាលមកពីដំណាំបង្កាត់ពូជ ........................... 243
សុវត្ថិភាពប្រសើរជាងការសោកស្តាយ ................................ 244
តើធ្វើដូចម្តេចទើបអ្នកដឹងថាគ្រាប់ពូជនិងអាហារគឺជាការបង្កាត់ពូជឬក៏មិនមែន? ....... 244
សាច់រឿង : គ្រាប់ពូជមេដ៏រឹងមាំ ................................ 245
អាហារបង្កាត់ពូជត្រូវបានប្រើជាជំនួយអាហារ ............................ 245
អ្នកសន្សំគ្រាប់ពូជក្នុងសហគមន៍ ................................... 246
សាច់រឿង : អ្នកភូមិរៀបចំការដោះដូរគ្រាប់ពូជ ........................ 246

# សន្យាមិនពិតនៃអាហារបង្កាត់ពូជ




ផ្លែប៉េងប៉ោះដែលមិនខូចបន្ទាប់ពីបេះរួច... ស្រូវសាឡី សណ្តែកសៀង និងពោតដែលអាចធន់នឹងថ្នាំសម្លាប់សត្វល្អិតយ៉ាងច្រើន... គ្រាប់ពូជដែលសម្លាប់សត្វល្អិតនៅក្នុងដី។ ទាំងអស់នេះមិនមែនជាវត្ថុធម្មជាតិទេ។ ប៉ុន្តែវាបែរជាមាននៅក្នុងលោកយើងនេះ។

រុក្ខជាតិប្រភេទថ្មីៗទាំងនេះត្រូវបានហៅថា អាហារបង្កាត់ពូជ ( GE: genetically engineered foods ) ឬអាហារកែច្នៃពូជ ( GM: genetically engineered foods ) ។ មិនមែនមនុស្សទាំងអស់យល់ស្របថាដំណាំថ្មីនេះមានសុខភាពទេ។ ក្រុមហ៊ុនសាជីវកម្មទាំងឡាយដែលផលិតអាហារនេះ និយាយថាវានឹងកែលម្អសន្តិសុខអាហារ, ជួយផ្គត់ផ្គង់អាហារដល់ពិភពលោក, ហើយក្នុងករណីឥន្ទនៈចម្រុះ ( មើលទំព័រ533 ) វាបញ្ចប់ភាពពឹងផ្អែកលើប្រេង។ មនុស្សខ្លះទៀតនិយាយថា វាបង្កគ្រោះថ្នាក់ដល់ប្រជាជននិងបរិស្ថាន។ ទោះបីអ្នកជឿលើអ្វីមួយក៏ដោយ ក៏កសិកម្មបច្ចុប្បន្ននិងអនាគត និងសន្តិសុខអាហារសម្រាប់យើងទាំងអស់គ្នាគឺកំពុងត្រូវបានផ្លាស់ប្តូរដោយដំណាំថ្មីៗទាំងនេះ។

ដំណាំបង្កាត់ពូជភាគច្រើនមិនផ្តល់ទិន្នផលដំណាំច្រើន សារធាតុចិញ្ចឹមប្រសើរ ឬផលប្រយោជន៍សុខភាពដែលអ្នកវិនិយោគបានអះអាងនោះទេ។ ហើយមកដល់ពេលនេះ ដំណាំបង្កាត់ពូជមិនបានជួយដល់អ្នកក្រីក្រ ឬដោះស្រាយបញ្ហាអត់ឃ្លាននៅឡើយទេ។ ដំណាំបង្កាត់ពូជភាគច្រើនត្រូវបានបង្កើតឡើងដើម្បីលក់ថ្នាំសម្លាប់សត្វល្អិតនិងជីគីមីបន្ថែមដែលផលិតដោយក្រុមហ៊ុនដូចគ្នាដែលផលិតនិងលក់គ្រាប់ពូជបង្កាត់។

អាហារបង្កាត់ពូជផ្តល់ដំណោះស្រាយបច្ចេកទេសមួយ ( គ្រាប់ពូជផលិតដោយមនុស្ស មានតម្លៃថ្លៃ ) សម្រាប់បញ្ហាសង្គម ៖ ភាពអត់ឃ្លាន។ ប៉ុន្តែនៅពេលកសិករពឹងផ្អែកលើការទិញគ្រាប់ពូជទាំងនេះ ព្រមទាំងថ្នាំសម្លាប់សត្វល្អិតនិងជីគីមីដែលត្រូវការផលិតដំណាំទាំងនេះ ភាពអត់ឃ្លានបែរជាកាន់តែកើនឡើង គឺមិនមែនថយចុះទេ។ សន្តិសុខអាហារមានទាប ហើយអធិបតេយ្យភាពអាហារក៏មានទាបដែរ។

## កសិករប្រឆាំងនឹងកប្បាសបង្កាត់ពូជ



បាសាន់ណា គឺជាកសិករដាំកប្បាសម្នាក់ រស់នៅក្នុងរដ្ឋកាណាតាកា នៃប្រទេសឥណ្ឌា។ ប៉ុន្មានឆ្នាំមុន នៅពេលដំណាំបង្កាត់ពូជទើបតែមានថ្មីៗ មានបុរសមួយក្រុមមកពីសាជីវកម្មម៉ុនសាន់តូ បានមកជួបគាត់ ហើយផ្តល់គ្រាប់ពូជកប្បាសថ្មីៗជាច្រើនឲ្យគាត់។ ពួកគេផ្តល់គ្រាប់ពូជដល់គាត់ដោយមិនយកប្រាក់ថែមទាំងជីសម្រាប់ជួយឲ្យវាលូតលាស់ទៀតផង។ ពួកគេប្រាប់គាត់ថាពួកគេនឹងត្រឡប់មកវិញពីរបីសប្តាហ៍ម្តងដើម្បីពិនិត្យមើលដំណាំនិងបាញ់ថ្នាំលើចម្ការរបស់គាត់។ សម្រាប់បាសាន់ណា វាហាក់ដូចជាជំនួញដ៏ល្អមួយ។ គាត់នឹងទទួលបានទិន្នផលកប្បាសដោយមិនអស់ប្រាក់ ហើយក្រុមហ៊ុននឹងធ្វើការងារស្ទើរតែទាំងអស់។

បាសាន់ណាមិនបានដឹងថាវាជាផ្នែកមួយនៃការពិសោធន៍លើការបង្កាត់ពូជដំណាំរបស់ក្រុមហ៊ុនម៉ុនសាន់តូទេ។ បុគ្គលិកក្រុមហ៊ុនម៉ុនសាន់តូ បានមកបាញ់ថ្នាំលើចម្ការរបស់គាត់ជាប្រចាំ ប៉ុន្តែដំណាំនៅតែមានដង្កូវកប្បាស និងសត្វល្អិតដទៃទៀត។ បាសាន់ណាឆ្ងល់ថាវាជាកប្បាសប្រភេទអ្វីបានជាបាញ់ថ្នាំសម្លាប់សត្វល្អិតច្រើនយ៉ាងនេះហើយ នៅតែមិនលូតលាស់ល្អ។

បាសាន់ណាបានដឹងថាកសិករដទៃទៀតកំពុងដាំកប្បាសថ្មីដូចគាត់ដែរ។ គាត់ក៏ដឹងដែរថាសមាគមកសិករក្នុងរដ្ឋកាណាតាកា មិនចូលចិត្តកប្បាសថ្មី ឬក្រុមហ៊ុនដែលផ្សព្វផ្សាយវាទេ។ បាសាន់ណាបានទៅចូលរួមការប្រជុំជាមួយកសិករទាំងនោះដើម្បីឲ្យយល់បន្ថែម។

បាសាន់ណាបានស្វែងយល់ថា កប្បាសថ្មីនេះត្រូវការជីគីមីច្រើនជាងកាលពីមុន ហើយជីគីមីទាំងនេះនឹងកាត់បន្ថយជីជាតិរបស់ដី។ គាត់ក៏បានស្វែងយល់ទៀតថា  កប្បាសថ្មីនេះអាចនឹងមិនផ្តល់ទិន្នផលច្រើនជាងកប្បាសចាស់របស់គាត់ទេ។ បាសាន់ណាបានឮថា គាត់នឹងមិនត្រូវបានអនុញ្ញាតឲ្យដាំកប្បាសឡើងវិញទេ ព្រោះក្រុមហ៊ុនមានសិទ្ធិលើកប្បាសនេះ។ អាក្រក់បំផុតនោះគឺគាត់ស្វែងយល់ថា លម្អងកប្បាសអាចហោះហើរតាមខ្យល់ រួចប៉ះពាល់ដំណាំរបស់អ្នកជិតខាង។ ប្រសិនបើដំណាំអ្នកជិតខាងត្រូវបានរោយលម្អងកប្បាសថ្មីនេះ នោះពួកគេនឹងមិនត្រូវបានអនុញ្ញាតឲ្យដាំដំណាំរបស់ខ្លួនឡើងវិញនៅឆ្នាំក្រោយទេ។

នៅពេលបាសាន់ណាដឹងថា កប្បាសបង្កាត់ពូជគឺជាការគំរាមកំហែងដល់កសិដ្ឋានគាត់ និងដល់សហគមន៍ទាំងមូល គាត់ក៏បានចូលរួមជាមួយសមាគមកសិករក្នុងរដ្ឋកាណាតាកា។ ពេលរួបរួមគ្នាហើយ កសិកររាប់ពាន់នាក់បានលើកផែនការមួយដើម្បីប្រាប់ពិភពលោកអំពីអ្វីដែលពួកគេយល់ឃើញចំពោះកប្បាសបង្កាត់ពូជ។ ពួកគេបានធ្វើផែនការសកម្មភាព បន្ទាប់មក, មួយថ្ងៃមុនពេលជួបជុំគ្នា, ពួកគេបានផ្ញើលិខិតមួយទៅឲ្យសារព័ត៌មានទាំងឡាយទូទាំងប្រទេស ដែលនិយាយថា :

> *ចម្ការចំនួន៣នឹងត្រូវដុតទៅជាផេះនៅថ្ងៃសៅរ៍នេះ។ ពួកសកម្មជនបានទាក់ទងម្ចាស់ចម្ការរួចហើយដើម្បីពន្យល់អំពីសកម្មភាពដែលយើងនឹងធ្វើ និងពីមូលហេតុនៃសកម្មភាពរបស់យើង និងដើម្បីប្រាប់ពួកគេថាយើងនឹងទទួលខុសត្រូវលើការខូចខាតរបស់ពួកគេ។ នៅពាក់កណ្តាលយប់ថ្ងៃសៅរ៍ កសិកររាប់ពាន់អ្នកនឹងទៅដល់ចម្ការទាំងនោះ ហើយនឹងដុតចម្ការនៅមុខកញ្ចក់កាមេរ៉ា ក្នុងសកម្មភាពប្រកាសបើកចំហរពីការមិនពេញចិត្ត។*

ថ្ងៃបន្ទាប់មក ពួកគេបានធ្វើតាមអ្វីដែលបានសន្យា។ ចម្ការទីមួយដែលត្រូវបានដុត គឺជារបស់បាសាន់ណា។ គាត់គាំទ្រការដុតចម្ការនេះ ព្រោះគាត់ខឹងថាក្រុមហ៊ុនម៉ុនសាន់តូមិនស្មោះត្រង់ជាមួយគាត់ ហើយថាកប្បាសបង្កាត់ពូជនឹងបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់ចម្ការនិងអ្នកជិតខាងរបស់គាត់។ ប្រាក់ដែល សមាគមកសិករបង់សងចម្ការរបស់គាត់ គាត់បានយកទៅទិញគ្រាប់ពូជកប្បាសបុរាណ ហើយត្រឡប់ទៅដាំដំណាំចម្រុះដែលធ្លាប់បានផ្តល់ផលល្អដល់គាត់។



### សំនួរសម្រាប់ការពិភាក្សា

- តើអ្នកធ្លាប់ដឹងថាមានកសិករបំផ្លាញដំណាំខ្លួនឯងទេ? តើអ្វីទៅដែលធ្វើឲ្យគាត់ឬអ្នក ធ្វើដូច្នេះ?
- តើអ្នកអាចគិតអំពីមធ្យោបាយដទៃទៀតដែលកសិករក្នុងរដ្ឋកាណាតាកាអាចធ្វើ ដើម្បីបង្ហាញពីការប្រឆាំងរបស់អ្នកចំពោះដំណាំបង្កាត់ពូជ?
- តើផលប្រយោជន៍នៃការដាំដំណាំបង្កាត់ពូជ"ដែលបានកែលម្អ" មានអ្វីខ្លះ?
- តើការចំណាយ"មើលមិនឃើញ" នៃដំណាំបង្កាត់ពូជ មានអ្វីខ្លះ?
- តើមានអ្វីខ្លះទៀតដែលអ្នកដឹងពីដំណាំបង្កាត់ពូជ?

## ការចិញ្ចឹម(បណ្តុះ)រុក្ខជាតិតាមបែបបុរាណ

វត្ថុមានជីវិតទាំងអស់សុទ្ធតែមានផ្នែកតូចល្អិតៗហៅថា ហ្សែន(ពូជ)។ ហ្សែនកំណត់ពីរបៀបលូតលាស់របស់រុក្ខជាតិ សត្វ ឬមនុស្សម្នាក់ៗ និងពីអ្វីដែលវានឹងក្លាយជា: ពីគ្រាប់ពូជទៅរុក្ខជាតិ, ពីស៊ុតទៅមាន់, ពីកុមារទៅមនុស្សធំ។

ដោយសារហ្សែនមានទំនាក់ទំនងជាមួយលក្ខខណ្ឌមួយចំនួន ដូចជាកម្តៅ ភាពត្រជាក់ ខ្យល់ គុណភាពដី ។ល។, ទើបហ្សែននៅក្នុងរុក្ខជាតិកំណត់ថាតើរុក្ខជាតិនឹងលូតលាស់ដោយរបៀបណា។ ហ្សែននៅក្នុងរុក្ខជាតិនីមួយៗកំណត់អំពីគុណភាព(ពណ៌ ទ្រង់ទ្រាយ និងទំហំ), ល្បឿននៃការលូតលាស់ (យឺតឬឆាប់), ពេលវេលាដែលវាចេញផ្កានិងផ្លែ, ឬសារធាតុចិញ្ចឹមអ្វីខ្លះដែលវាមាន។

នៅពេលកសិករជ្រើសរើសនិងសន្សំទុកនូវពូជពោតដែលធំបំផុតបន្ទាប់ពីប្រមូលផលរួច សម្រាប់ដាំនៅឆ្នាំក្រោយ, ហ្សែនរបស់ពូជធំៗត្រូវបានផ្ទេរពីដំណាំមួយទៅដំណាំមួយទៀតជាច្រើនឆ្នាំ ហើយហ្សែនរបស់ពូជតូចៗនឹងបាត់បង់។ នេះគឺជាដំណើរការនៃ**ការចិញ្ចឹមរុក្ខជាតិ**។ វាគឺជាដំណើរការយឺតៗនៃការជ្រើសរើស(និងជួយឲ្យមាន)លក្ខណៈរបស់រុក្ខជាតិមួយដែលកសិករចង់បាន។



**តាមរយៈការជ្រើសរើសគ្រាប់ពូជល្អៗ អ្នកអាចជួយឲ្យដំណាំនៅរដូវក្រោយកាន់តែរឹងមាំ។**

# តើរុក្ខជាតិបង្កាត់ពូជខុសពីការចិញ្ចឹមរុក្ខជាតិតាមបែបបុរាណយ៉ាងដូចម្ដេច?

ការបង្កាត់ពូជខុសពីការចិញ្ចឹមរុក្ខជាតិ។ អ្នកវិទ្យាសាស្ត្រប្រើវិធីសាស្ត្រក្នុងមន្ទីរពិសោធន៍ដើម្បីកែប្រែហ្សែនរបស់រុក្ខជាតិឬសត្វ ក្នុងវិធីដ៏ស្មុគស្មាញ ជាងការចិញ្ចឹមរុក្ខជាតិតាមបែបបុរាណ។ ដើម្បីទទួលបានគុណភាពរុក្ខជាតិដែលខ្លួនចង់បាន ពួកគេអាចយកហ្សែនរបស់រុក្ខជាតិ២ខុសគ្នាស្រឡះ(ដូចជាស្រូវ និងពោត) មកបញ្ចូលគ្នា។ ពួកគេក៏អាចរួមបញ្ចូលគ្នារវាងហ្សែនរុក្ខជាតិនិងហ្សែនសត្វផងដែរ។ ដោយមូលហេតុនេះហើយទើបគេហៅវិធីនេះថា "ការបង្កាត់ពូជ" ។ ក៏ដូចជាវិស្វករដែរ អ្នកវិទ្យាសាស្ត្រផ្នែករុក្ខជាតិ "សាងសង់" រុក្ខជាតិនិងសត្វប្រភេទថ្មីៗដែលធម្មជាតិមិនអាចបង្កើតបានឡើយ។

រុក្ខជាតិបង្កាត់ពូជ មិនមែនគ្រាន់តែជាភាពចម្រុះថ្មីៗជាមួយនឹងគុណភាពប្រសើរទេ។ វាគឺជារុក្ខជាតិប្រភេទថ្មីដែលមិនធ្លាប់មានពីមុនមក។ ជារៀងរាល់ឆ្នាំ ក្រុមហ៊ុនសាជីវកម្មនានាចំណាយប្រាក់រាប់កោដិដុល្លាក្នុងការច្នៃប្រឌិតការបង្កាត់ពូជថ្មីៗ ដូចជាដើមឈើដែលលូតលាស់ឆាប់រហ័ស និងមានឈើទន់ៗសម្រាប់ធ្វើក្រដាស, ផ្លែប៉េងប៉ោះដែលរក្សាភាពស្រស់នៅពេលរក្សាទុករយៈពេលយូរ, សណ្ដែកសៀង ស្រូវសាឡី និងកប្បាសដែលអាចស៊ូទ្រាំនឹងថ្នាំសម្លាប់សត្វល្អិតយ៉ាងច្រើន, និងសត្វដូចជាត្រីនិងជ្រូកដែលលូតលាស់ធំជាងធម្មតាយ៉ាងខ្លាំង។

## ការចំណាយខ្ពស់លើដំណាំបង្កាត់ពូជ

ការដាំដំណាំបង្កាត់ពូជ មានតម្លៃថ្លៃជាងការដាំដំណាំបុរាណក្នុងវិធីមានស្ថិរភាព។ ជំនួសឲ្យការសន្សំគ្រាប់ពូជពីដំណាំមុនៗ កសិករត្រូវតែទិញគ្រាប់ពូជដែលបានបង្កាត់ជារៀងរាល់ឆ្នាំ ព្រមទាំងជីគីមីនិងថ្នាំសម្លាប់សត្វល្អិតដែលមានតម្លៃថ្លៃ។ ដំណាំបង្កាត់ពូជក៏អាចមានការចំណាយ"មើលមិនឃើញ"ជាច្រើនផងដែរ។ វាអាចមិនសូវមានសារធាតុចិញ្ចឹម និងអាចបំផ្លាញបរិស្ថាន(មើលទំព័រ243)។ មុននឹងដាំដំណាំបង្កាត់ពូជ សូមពិចារណាលើការចំណាយដទៃទៀតដែលភាគច្រើនគឺ"មើលមិនឃើញ"។



# អាហារបង្កាត់ពូជ និងសុខភាព

ផលប៉ះពាល់មួយចំនួនពីដំណាំបង្កាត់ពូជមកលើសុខភាព ត្រូវបានគេដឹងព្រោះប្រជាជនបានធ្លាក់ខ្លួនឈឺនៅពេលហូបវា។ បញ្ហាសុខភាពដទៃទៀតត្រូវបានគេសង្ស័យ ប៉ុន្តែនៅមិនទាន់មានការបញ្ជាក់ច្បាស់លាស់ទេ។

ទីភ្នាក់ងាររដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក និងប្រទេសដទៃទៀតដែលផលិតដំណាំបង្កាត់ពូជ បដិសេធមិនធ្វើតេស្តលើផលប៉ះពាល់សុខភាពដែលអាចកើតមានឡើយ។ សាជីវកម្មដែលបង្កើតដំណាំទាំងនេះ ធ្វើអ្វីគ្រប់យ៉ាងដើម្បីកុំឲ្យមានការធ្វើតេស្តនេះ។ ដំណាំបង្កាត់ពូជនិងអាហារផលិតពីដំណាំនេះ ភាគច្រើនមិនមានបិទស្លាកសញ្ញាទេ ហើយដាក់លក់ឡុកឡំជាមួយដំណាំនិងអាហារធម្មតា។ របៀបនេះធ្វើឲ្យយើងពិបាកដឹងថាអាហារបង្កាត់ពូជមានគ្រោះថ្នាក់ឬអត់ ឬនរណាម្នាក់ធ្លាក់ខ្លួនឈឺដោយសារបរិភោគដំណាំបង្កាត់ពូជឬក៏អត់។




## បញ្ហាសុខភាពបណ្ដាលមកពីដំណាំបង្កាត់ពូជ

ដើម្បីឲ្យដឹងពីបញ្ហាសុខភាពនៃដំណាំបង្កាត់ពូជ ទាមទារឲ្យមានការសិក្សាច្រើនឆ្នាំ។ អ្នកវិទ្យាសាស្ត្របានធ្វើការសិក្សាខ្លះៗរួចមកហើយដែលបង្ហាញថាដំណាំបង្កាត់ពូជប្រហែលជាធ្វើឲ្យមានបញ្ហាសុខភាពពិតមែន ៖

### អាល់ឡែស៊ី

អាហារដែលផលិតមកពីដំណាំបង្កាត់ពូជ មានផ្ទុកសារធាតុដែលមនុស្សមិនធ្លាប់បរិភោគកន្លងមក។ នេះអាចធ្វើឲ្យរាងកាយរបស់មនុស្សមានប្រតិកម្មអាក្រក់ទៅនឹងអាហារទាំងនេះ។ ដោយសារតែយើងមិនដឹងជាមុនថាសារធាតុអ្វីនៅក្នុងដំណាំបង្កាត់ពូជ ធ្វើឲ្យមានអាល់ឡែស៊ី នោះទើបប្រជាជនអាចមានអាល់ឡែស៊ីនឹងអាហារជាច្រើនដែលពួកគេបរិភោគញឹកញាប់។

### ការកើនឡើងនៃការពុលថ្នាំសម្លាប់សត្វល្អិត

ដំណាំបង្កាត់ពូជភាគច្រើន លូតលាស់បានល្អតែនៅពេលដែលបន្ថែមសារធាតុគីមីយ៉ាងច្រើនប៉ុណ្ណោះ។ គ្រាប់ពូជបង្កាត់ខ្លះថែមទាំងត្រូវបានបង្កើតឡើងឲ្យមានផ្ទុកជាតិថ្នាំសម្លាប់សត្វល្អិតទៀតផង។ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតមានកំណត់ អាចផ្ដល់ប្រយោជន៍ដល់កសិករ។ ប៉ុន្តែការប្រើប្រាស់ច្រើនពេក បណ្ដាលឲ្យមានការពុលថ្នាំសម្លាប់សត្វល្អិតកាន់តែច្រើន ទាំងចំពោះមនុស្សនិងបរិស្ថាន(មើលជំពូក14)។

### ជំងឺមហារីក និងការខូចសរីរាង្គ

សត្វដែលស៊ីដំឡូងនិងប៉េងប៉ោះបង្កាត់ពូជ មានការផ្លាស់ប្ដូរនៅក្នុងក្រពះរបស់ពួកវា ដែលនាំឲ្យមានជំងឺមហារីក, ខូចតម្រងនោម និងសរីរាង្គដទៃទៀត, និងខួរក្បាលលូតលាស់ខ្សោយ។ ប៉ុន្តែនៅពេលគ្មានការធ្វើតេស្តឬបិទស្លាកសញ្ញានៅលើអាហារបង្កាត់ពូជទេ នោះវេជ្ជបណ្ឌិតមិនអាចដឹងថាជំងឺមហារីកឬការខូចសរីរាង្គរបស់មនុស្សម្នាក់ គឺបណ្ដាលមកពីអាហារបង្កាត់ពូជពិតមែនឬអត់នោះទេ។

## ការស៊ាំនឹងថ្នាំអង់ទីប៊ីយោទិក

អាហារបង្កាត់ពូជខ្លះបានដាក់បញ្ចូលនូវហ្សែនដែលស៊ាំនឹង**ថ្នាំអង់ទីប៊ីយោទិក។** អ្នកវិទ្យាសាស្ត្រខ្លះជឿថា នៅពេលប្រជាជនបរិភោគអាហារដែលមានហ្សែនបែបនេះ មេរោគដែល**ស៊ាំនឹងថ្នាំអង់ទីប៊ីយោទិក**នឹងមាននៅក្នុងក្រពះពួកគេ។ បន្ទាប់មក ប្រសិនបើអ្នកនោះត្រូវការប្រើថ្នាំអង់ទីប៊ីយោទិកដើម្បីព្យាបាលជំងឺ នោះថ្នាំនេះអាចលែងមានប្រសិទ្ធភាពតទៅទៀត។

### ស្រូវមាសនៅអាស៊ី

នៅជុំវិញពិភពលោក មនុស្សរាប់លាននាក់រងគ្រោះពីភាពពិការភ្នែក ដោយសារខ្វះវីតាមីនអានៅក្នុងរបបអាហាររបស់ខ្លួន។ ដើម្បីជាដំណោះស្រាយចំពោះបញ្ហានេះ ស្រូវបង្កាត់ពូជថ្មីមួយប្រភេទដែលមានវីតាមីនអា ត្រូវបានបង្កើតឡើងនិងដាក់ឈ្មោះថា "ស្រូវមាស"។ ក្រុមហ៊ុនដែលផលិត"ស្រូវមាស" មានគម្រោងលក់ស្រូវនេះទៅកសិករនៅទូទាំងទ្វីបអាស៊ីដែលជាប្រទេសបរិភោគស្រូវចម្បងគេ និងជាប្រទេសដែលភាពពិការភ្នែកគឺជាបញ្ហាដ៏ធ្ងន់ធ្ងរ។ ក្រុមហ៊ុននេះសង្ឃឹមថាកសិករនឹងដាំ"ស្រូវមាស" ជំនួសស្រូវបុរាណដែលមានភាពចម្រុះ។

ប៉ុន្តែ "ស្រូវមាស"មិនបានបង្ការមិនឲ្យប្រជាជនពិការភ្នែក។ ភាពពិការភ្នែកដែល"ស្រូវមាស"កំពុងព្យាយាមដោះស្រាយ គឺមិនមែនបណ្តាលមកពីកង្វះវីតាមីនអាតែមួយមុខទេ។ វាបណ្តាលមកពីកង្វះអាហារសុខភាពចម្រុះ ដែលមានវីតាមីនអាពីធម្មជាតិ។



របបអាហារសុខភាព រាប់បញ្ចូលទាំងបន្លែនិងផ្លែឈើផងដែរ។

បើទោះជាមនុស្សម្នាក់បរិភោគ"ស្រូវមាស"ក៏ដោយ ក៏វីតាមីនអាមិនអាចចិញ្ចឹមគាត់ឡើយ លុះត្រាតែមានសារជាតុចិញ្ចឹមគ្រប់គ្រាន់ពីអាហារដទៃទៀតដែលបរិភោគក្នុងពេលជាមួយគ្នា។

ជាជាងការសាកល្បងដំណោះស្រាយបច្ចេកទេស, ដូចជាស្រូវបង្កាត់ពូជដើម្បីបង្ការភាពពិការភ្នែកនិងបញ្ហាដទៃទៀតនៃភាពអត់ឃ្លាន, ជាការប្រសើរគួរតែកែលម្អសន្តិសុខអាហារវិញ។ ដោយសារតែអ្នកវិនិយោគ"ស្រូវមាស"មិនជំនះនឹងបញ្ហាពិតប្រាកដនៃភាពក្រីក្រនិងកង្វះអាហារូបត្ថម្ភ នោះពួកគេនឹងមិនអាចបង្ការប្រជាជនពីភាពពិការភ្នែកបានឡើយ។

## មធ្យោបាយល្អប្រសើរក្នុងការបញ្ចប់បញ្ហាផ្សេងៗដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ

"ស្រូវមាស"គឺជាឧទាហរណ៍មួយនៃការព្យាយាមដោះស្រាយបញ្ហាសង្គម (ភាពពិការភ្នែកដែលបណ្តាលមកពីភាពក្រីក្រនិងកង្វះអាហារូបត្ថម្ភ) ដោយប្រើដំណោះស្រាយបច្ចេកទេស : ដំណាំបង្កាត់ពូជ។ ប៉ុន្តែយើងមានដំណោះស្រាយមួយផ្សេងទៀត។

វីតាមីនអាមានយ៉ាងច្រើននៅក្នុងផ្លែឈើថ្មីស្រស់ បន្លែស្លឹកពណ៌បៃតងចាស់ និងអាហារដទៃទៀត។ (សម្រាប់ព័ត៌មានបន្ថែមអំពីអាហារូបត្ថម្ភល្អ សូមអានសៀវភៅសុខភាពទូទៅ ដូចជា *ទីណាគ្មានវេជ្ជបណ្ឌិត* ជាដើម)។ បន្លែបៃតងធ្លាប់បានដុះយ៉ាងច្រើនក្រៃលែងនៅក្នុងស្រែនិងចម្ការរបស់កសិករ ប៉ុន្តែវាបាត់ទៅវិញ ដោយសារតែការកើនឡើងនៃការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិ។

នៅប្រទេសបង់ក្លាដេស ប្រជាជនបានរៀបចំដាំសួនដំណាំតាមផ្ទះ ដើម្បីប្រាកដថាកុមារទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់។ ដោយមានជំនួយពីអង្គការហេលេនខិល័រអន្តរជាតិ( Helen Keller International ) ប្រជាជនបានដាំសួនដំណាំតាមផ្ទះចំនួន៦០០.០០០សួន ដើម្បីជួយបង្ការភាពពិការភ្នែក និងបញ្ហាសុខភាពដទៃទៀតដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ។ សួនដំណាំតាមផ្ទះ គឺជាមធ្យោបាយមួយក្នុងការកែលម្អអាហារូបត្ថម្ភ និងសន្តិសុខអាហារ ដោយមិនចាំបាច់រកមើលដំណោះស្រាយបច្ចេកទេសដែលមានតម្លៃថ្លៃដូចជាអាហារបង្កាត់ពូជ ដែលអាចនឹងគ្មានប្រសិទ្ធភាពសោះ។

# បញ្ហាបរិស្ថានបណ្តាលមកពីដំណាំបង្កាត់ពូជ

នៅពេលសាជីវកម្មធំៗផលិតនិងលក់តែគ្រាប់ពូជពីរបីប្រភេទ ហើយបញ្ចុះបញ្ចូលកសិករទូទាំងពិភពលោកឲ្យប្រើប្រាស់តែគ្រាប់ពូជទាំងនេះ នោះរុក្ខជាតិផ្សេងៗគ្នាជាច្រើនប្រភេទទៀតអាចនឹងបាត់បង់ ហើយសន្តិសុខអាហារនឹងមានគ្រោះថ្នាក់។ ប៉ុន្តែផលប៉ះពាល់ដ៏គ្រោះថ្នាក់បំផុតដែលដំណាំបង្កាត់ពូជមានលើបរិស្ថាន គឺការបាត់បង់ជីវចម្រុះ( មើលទំព័រ27 ) ដែលមានសារសំខាន់សម្រាប់សុខភាពបរិស្ថាន។

**ការបាត់បង់ការគ្រប់គ្រងសត្វល្អិតតាមបែបធម្មជាតិ។** ដំណាំបង្កាត់ពូជខ្លះ ត្រូវបានផលិតឡើងដោយមានថ្នាំសម្លាប់សត្វល្អិតនៅក្នុងនោះ។ នៅពេលថ្នាំសម្លាប់សត្វល្អិតត្រូវបានប្រើប្រាស់ដោយគ្មានការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ន នោះសត្វល្អិតដែលធម្មតាគេអាចសម្លាប់វាបាន អាចស៊ាំនឹងថ្នាំទាំងនេះ( មើលទំព័រ273 )។

**ការបង្កគ្រោះថ្នាក់ដល់សត្វព្រៃនិងដី។** ថ្នាំសម្លាប់សត្វល្អិតដែលមាននៅក្នុងដំណាំបង្កាត់ពូជ សម្លាប់សត្វល្អិតនិងបាក់តេរីមានប្រយោជន៍ដែលរស់នៅក្នុងដី។ វាក៏អាចបង្កគ្រោះថ្នាក់ដល់សត្វស្លាប ប្រចៀវ និងសត្វដទៃទៀត ដែលជួយរោយលម្អងរុក្ខជាតិនិងគ្រប់គ្រងសត្វល្អិត។

**ផលប៉ះពាល់លើរុក្ខជាតិជិតខាង។** លម្អងចេញពីដំណាំបង្កាត់ពូជ ហើរនៅក្នុងខ្យល់ និងរាយប៉ាយទៅលើរុក្ខជាតិដទៃទៀតដែលស្រដៀងនឹងវា។ ប៉ុន្តែដោយសាររុក្ខជាតិបង្កាត់ពូជទើបបានបង្កើតថ្មី ទើបគ្មាននរណាម្នាក់ដឹងច្បាស់ទេថាផលប៉ះពាល់យូរអង្វែងនៃការសាយលម្អងនេះមានអ្វីខ្លះ។




**កសិករទទួលរងគ្រោះនៅពេលដំណាំបង្កាត់ពូជបង្កគ្រោះថ្នាក់ដល់បរិស្ថាន។**

## សុវត្ថិភាពប្រសើរជាងការសោកស្តាយ

សុភាសិតអាហ្វ្រិកមួយពោលថា "ប្រសិនបើអ្នកត្រូវវាស់ជម្រៅទន្លេ ចូរលូកតែជើងម្ខាងចូលសិន។ ធ្វើរបៀបនេះអ្នកមិនប្រថុយនឹងការលង់ទឹកទេ"។ នេះគឺជារបៀបម្យ៉ាងទៀតក្នុងការនិយាយថា ជាការប្រសើរត្រូវធ្វើអ្វីមួយដោយមានការប្រុងប្រយ័ត្ន និងត្រូវធ្វើតាម**គោលការណ៍ប្រុងប្រយ័ត្នជាមុន**(មើលទំព័រ32)។ នៅពេលយើងពិចារណាលើការប្រើប្រាស់ការបង្កើតថ្មីនិងសារធាតុថ្មីៗ ល្អបំផុតគឺយើងត្រូវដឹងថាវាមានសុវត្ថិភាពជាជាងការប្រថុយនឹងគ្រោះថ្នាក់ដែលមិនចាំបាច់។

ប៉ុន្តែសាជីវកម្មនិងរដ្ឋាភិបាលកំពុងធ្វើតេស្ត៍លើអាហារបង្កាត់ពូជមកលើពួកយើងរាល់ថ្ងៃ តាមរយៈការបង្គាប់ឲ្យយើងដាំនិងបរិភោគវា ដោយមិនដឹងពីគ្រោះថ្នាក់ដែលវាអាចកើតមានទេ។ ពួកគេកំពុងតែបង្ខំពួកយើងឲ្យ "វាស់ជម្រៅទន្លេ" ដោយលូកជើងទាំងពីរចូលតែម្តង!




## តើធ្វើដូចម្តេចទើបអ្នកដឹងថាគ្រាប់ពូជនិងអាហារគឺជាការបង្កាត់ពូជឬក៏មិនមែន?

គ្រាប់ពូជបង្កាត់ភាគច្រើន មិនមានរូបរាង ក្លិន ឬរសជាតិខុសគ្នាពីគ្រាប់ពូជធម្មតានោះទេ ដូច្នេះវាអាចត្រូវបានដាំដោយកសិករដែលមិនដឹងថាវាជាអ្វីឡើយ។ ម៉ុនសាន់តូ, ដែលជាក្រុមហ៊ុនផលិតអាហារបង្កាត់ពូជភាគច្រើន, បានបដិសេធមិនព្រមបិទស្លាកសញ្ញាថាជាអាហារបង្កាត់ពូជទេ ដូច្នេះប្រជាជនដែលបរិភោគវាមិនអាចដឹងថាវាជាអាហារបង្កាត់ពូជទេ។ វិធីតែមួយគត់ដើម្បីឲ្យដឹងថាគ្រាប់ពូជនិងអាហារជាការបង្កាត់ពូជឬក៏មិនមែន គឺត្រូវធ្វើតេស្ត៍លើរចនាសម្ព័ន្ធនៃហ្សែនរបស់វា។ ឧបករណ៍សម្រាប់ធ្វើតេស្ត៍នេះ មានលក់នៅសហរដ្ឋអាមេរិកនិងអឺរ៉ុប ប៉ុន្តែវាមានតម្លៃថ្លៃ។

### គ្រាប់ពូជមេដ៏រឹងមាំ

នៅជាប៉ាស នៃប្រទេសម៉ិកស៊ិកូ កសិករមានការបារម្ភជាខ្លាំងអំពីលម្អងរបស់ដំណាំបង្កាត់ពូជដែលអាចប៉ះពាល់ដល់ដំណាំពោតរបស់ខ្លួន។ ដោយមានជំនួយពីអ្នកគាំទ្រអន្តរជាតិ ពួកគាត់បានរកឃើញវិធីមួយក្នុងការធ្វើតេស្តដំណាំរបស់ខ្លួន ថាតើវារងការប៉ះពាល់ឬទេ។ គម្រោងនេះហៅថា "គ្រាប់ពូជមេដ៏រឹងមាំ"។

គ្រាប់ពូជត្រូវបានធ្វើតេស្តដោយឧបករណ៍ដែលទិញមកពីក្រុមហ៊ុនក្នុងប្រទេសអឺរ៉ុបឬសហរដ្ឋអាមេរិក។ តាមរយៈការស្វែងយល់ថាតើដំណាំរបស់ពួកគាត់មានការប៉ះពាល់ពីពោតបង្កាត់ពូជឬអត់ ពួកគាត់អាចប្រាប់សហគមន៍និងអាជ្ញាធររបស់ខ្លួនអំពីបញ្ហានេះ ហើយធ្វើការងាររួមគ្នាដើម្បីបង្ការបញ្ហានេះមិនឲ្យរាលដាលតទៅទៀត។ ដោយសារតែពួកគាត់ធ្វើតេស្តលើគ្រាប់ពូជដោយខ្លួនឯង ទើបកសិករអាចគ្រប់គ្រងលើដំណើរការនេះ -- ជាការគ្រប់គ្រងមួយប្រភេទដែលបានបាត់បង់ដោយការមិនបានដឹងថាមានអ្វីខ្លះនៅក្នុងដំណាំដែលខ្លួនកំពុងដាំ។

តាមរយៈការគ្រប់គ្រងលើដំណាំរបស់ខ្លួនឡើងវិញ កសិករនៅជាប៉ាសកំពុងតែការពារសន្តិសុខអាហាររបស់ខ្លួន ខណៈដែលអនុវត្តអធិបតេយ្យភាពអាហារយូរអង្វែង។

# អាហារបង្កាត់ពូជត្រូវបានប្រើជាជំនួយអាហារ




មានប្រទេសជាច្រើនមិនអនុញ្ញាតឲ្យអាហារបង្កាត់ពូជដាំដុះឬនាំចូលទៅក្នុងប្រទេសឡើយ។ ប៉ុន្តែសូម្បីតែក្នុងប្រទេសទាំងនេះក៏ដោយ ក៏អាហារបង្កាត់ពូជអាចរកវិធីចូលទៅក្នុងការផ្គត់ផ្គង់អាហារបានដែរ។ នៅប្រទេសក្រីក្រ វិធីមួយដែលអាហារបង្កាត់ពូជចូលទៅក្នុងទីផ្សារនិងស្រែចម្ការ គឺតាមរយៈជំនួយអាហារ។

នៅពេលប្រទេសជួបភាពអត់ឃ្លានធ្ងន់ធ្ងរ ពួកគេច្រើនតែទទួលជំនួយក្នុងទម្រង់ជាធញ្ញជាតិពីអង្គការសហប្រជាជាតិឬពីប្រទេសដាច់ដោយឡែកដទៃទៀត។ ប្រទេសដែលផលិតធញ្ញជាតិបង្កាត់ពូជ ច្រើនតែផ្តល់វាជាជំនួយអាហារ។ បញ្ហានេះបង្ខំឲ្យកសិករ ប្រជាជនអត់ឃ្លាន និងរដ្ឋាភិបាលរបស់ពួកគេ ឲ្យជ្រើសរើសរវាងអាហារបង្កាត់ពូជ និងការដាច់ពោះ។

ប៉ុន្តែជួនកាល, សូម្បីតែក្នុងស្ថានភាពគ្រោះមហន្តរាយក្តី, រដ្ឋាភិបាលខ្លះបានប្រកាន់ជំហររបស់ខ្លួន។ ឧទាហរណ៍ ប្រទេសហ្សាមប៊ៀ និងហ្ស៊ីមបាវ៉េ ត្រូវបានផ្តល់ជំនួយអាហារជាពោតបង្កាត់ពូជ នៅរដូវរងារក្នុងឆ្នាំ២០០២ដែលជាពេលវេលានៃភាពអត់ឃ្លានដ៏ធ្ងន់ធ្ងរ។ ប្រទេសហ្សាមប៊ៀបានបដិសេធជំនួយអាហារបង្កាត់ពូជ។ បន្ទាប់ពីការសម្រេចរបស់ពួកគេ អ្នកផ្តល់ជំនួយអន្តរជាតិបានផ្តល់ឲ្យប្រទេសហ្សាមប៊ៀនូវប្រាក់សម្រាប់ទិញអាហារពីប្រទេសដទៃក្នុងទ្វីបអាហ្វ្រិកដែលបានផលិតអាហារលើសធម្មតា។ ប្រទេសអឺរ៉ុបខ្លះដែលអាហារបង្កាត់ពូជជាការខុសច្បាប់ បានឆ្លើយតបដោយការផ្តល់ជំនួយអាហារដែលគ្មានធញ្ញជាតិបង្កាត់ពូជ។

រដ្ឋាភិបាលហ្ស៊ីមបាវ៉េ ក៏មានសម្ពាធពីប្រជាជនអត់ឃ្លានជាច្រើនដែរ។ ហ្ស៊ីមបាវ៉េបានទទួលជំនួយអាហារបង្កាត់ពូជ ប៉ុន្តែបានធ្វើកិច្ចព្រមព្រៀងថា ពោតត្រូវកិន(ក្នុងរោងម៉ាស៊ីន)ឲ្យហើយ ដើម្បីកុំឲ្យវាអាចដាំឡើងវិញបាន និងបង្កបញ្ហាទៅថ្ងៃក្រោយ។

# អ្នកសន្សំគ្រាប់ពូជក្នុងសហគមន៍




នៅទូទាំងពិភពលោក សហគមន៍កំពុងឆ្លើយតបទៅនឹងការគំរាមកំហែងនៃដំណាំបង្កាត់ពូជ។ ប្រជាជនខ្លះទាមទារឲ្យរដ្ឋាភិបាលបិទស្លាកសញ្ញាសម្គាល់ថាជាអាហារបង្កាត់ពូជ ដើម្បីឲ្យគេអាចចៀសវាងទិញឬបរិភោគវាបាន។ អ្នកខ្លះទៀតបដិសេធមិនឲ្យមានដាំដំណាំបង្កាត់ពូជនៅក្នុងភូមិភាគរបស់ខ្លួនឡើយ។ សហគមន៍ជាច្រើនបានត្រឡប់ទៅរកវិធីបុរាណគឺការសន្សំគ្រាប់ពូជ និង**ការកាន់កាប់គ្រាប់ពូជក្នុងសហគមន៍។**

ការកាន់កាប់គ្រាប់ពូជក្នុងសហគមន៍ គឺនៅពេលដែលសហគមន៍គ្រប់គ្រងគ្រាប់ពូជដែលខ្លួនមាន, សន្សំគ្រាប់ពូជចម្រុះសម្រាប់ដាំនៅថ្ងៃមុខ, នឹងកត់ត្រាច្បាស់លាស់អំពីគ្រាប់ពូជទាំងនេះ។ តាមរបៀបនេះ សហគមន៍ថែរក្សាធនធានគ្រាប់ពូជសំខាន់ៗឲ្យនៅមានជីវិត និងការពារជីវចម្រុះ។ ម្យ៉ាងទៀត ពួកគេអាចបង្ការមិនឲ្យមានអ្នកខាងក្រៅមកទាមទារកម្មសិទ្ធិលើគ្រាប់ពូជបុរាណរបស់ពួកគេ។

រដ្ឋាភិបាលអាចនិងគួរតែរក្សាឲ្យបាននូវឃ្លាំងគ្រាប់ពូជជាតិ ដើម្បីធានាថាប្រជាជនមានដំណាំខុសៗគ្នាយ៉ាងច្រើន និងដើម្បីបង្ការរុក្ខជាតិនីមួយៗមិនឲ្យខ្វះខាតឬបាត់បង់។ ការគ្រប់គ្រងលើការផ្គត់ផ្គង់គ្រាប់ពូជ គឺជាចំណុចសំខាន់សម្រាប់សន្តិសុខអាហារ និងអធិបតេយ្យភាពអាហារ។

## អ្នកភូមិរៀបចំការដោះដូរគ្រាប់ពូជ

អ្នកភូមិវីសិនទីហ្គេរេរ៉ូ(Vicente Guerrero) នៃប្រទេសម៉ិកស៊ិកូ មានការបារម្ភជាខ្លាំងអំពីការបាត់បង់គ្រាប់ពូជបុរាណរបស់ខ្លួន។ មនុស្សចាស់នៅក្នុងភូមិនៅចាំថាកាលពីមុនមានពោតជាច្រើនប្រភេទខុសៗគ្នា ហើយសណ្តែកមានរឹតតែច្រើន។ ឥឡូវនេះមានពោតតែ២ប្រភេទ និងសណ្តែក៤ប្រភេទប៉ុណ្ណោះ។ ពួកគេដឹងថាក្រុមហ៊ុនលក់គ្រាប់ពូជ កំពុងផលិតគ្រាប់ពូជថ្មីៗដែលអាចប្រើប្រាស់តែ១ឆ្នាំប៉ុណ្ណោះ ឬត្រូវការជីគីមីថ្លៃៗដើម្បីឲ្យវាលូតលាស់។ ដូច្នេះអ្នកភូមិបានសម្រេចចិត្តធ្វើអ្វីមួយ។

អ្នកភូមិបានអញ្ជើញប្រជាជននៅក្នុងភូមិភាគ ឲ្យចូលរួមពិធីជប់លៀងដ៏ធំមួយ ហើយប្រាប់អ្នកទាំងអស់គ្នាឲ្យយកអាហារមកចម្អិន និងគ្រាប់ពូជដែលពួកគេចូលចិត្តមកជាមួយផង។ ប្រជាជននឹងដោះដូរគ្រាប់ពូជទៅវិញទៅមក, ចម្អិនអាហារដោយប្រើដំណាំដែលខ្លួនចូលចិត្ត, និងនិយាយរឿងរ៉ាវប្រាប់គ្នាអំពីទីកន្លែងដែលគេយកដំណាំនេះមក និងថាតើគេដាំវាដោយរបៀបណា។ ការប្រជុំនេះហៅថា ការដោះដូរគ្រាប់ពូជ។

កសិករខ្លះបានយកពោតនិងសណ្តែកយ៉ាងច្រើនប្រភេទដែលអ្នកដទៃមិនដែលឃើញសោះច្រើនឆ្នាំមកហើយ។ ពួកគេចែកគ្រាប់ពូជឲ្យអ្នកដទៃយកទៅដាំ។ នៅឆ្នាំនោះ មានពោត៥ប្រភេទ និងសណ្តែក៨ប្រភេទ នៅកន្លែងដោះដូរគ្រាប់ពូជ។ នៅឆ្នាំបន្ទាប់ ព័ត៌មានអំពីការដោះដូរគ្រាប់ពូជ បានផ្សព្វផ្សាយនៅទូទាំងភូមិភាគ ហើយកសិករខ្លះបាននាំយកគ្រាប់ពូជខ្លះដែលសូម្បីតែជីដូនជីតារបស់ពួកគេមិនធ្លាប់ឃើញសោះតាំងពីក្មេងមក។



ពីរបីឆ្នាំក្រោយមក ភូមិនេះប្រមូលបានពោតជាង២០ប្រភេទ និងសណ្តែកជាង៤០ប្រភេទ។ ភាពចម្រុះនៃដំណាំនេះ ធ្វើឲ្យប្រាកដថាពោតនិងសណ្តែកនឹងលូតលាស់ជារៀងរាល់ឆ្នាំ ព្រោះពោតនិងសណ្តែកខ្លះអាចលូតលាស់ល្អបំផុតនៅជាយភ្នំស្ងួតៗ ខ្លះទៀតត្រូវការជ្រលងសើមៗ និងខ្លះទៀតត្រូវការដីរាប ។ល។ និង ។ល។ ប្រជាជនជាច្រើននៅក្នុងភូមិវីសិនទីហ្គីរេរ៉ូ បានចាប់ផ្តើមដាំដំណាំទាំងនេះ ហើយសព្វថ្ងៃអ្នកភូមិមិនបារម្ភពីការបាត់បង់ការគ្រប់គ្រងលើគ្រាប់ពូជរបស់ខ្លួនឡើយ។ តាមរយៈការបរិភោគរុក្ខជាតិចម្រុះ ពួកគេក៏បានកែលម្អរបបអាហាររបស់ខ្លួនផងដែរ។

សព្វថ្ងៃ ភូមិដទៃៗទៀតនៅក្នុងភូមិភាគ កំពុងតែដោះដូរគ្រាប់ពូជ ហើយដំណាំចាស់ៗជាច្រើនកំពុងត្រឡប់មកវិញ។ កសិករក្នុងភូមិវីសិនទីហ្គីរេរ៉ូ និយាយថា ការដាំដំណាំចាស់ៗមិនត្រឹមតែកែលម្អសន្តិសុខអាហាររបស់ពួកគេ ប៉ុន្តែវាក៏ជាមូលហេតុដ៏សំខាន់នៃការប្រារព្ធពិធីជប់លៀងដ៏ធំ!